**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚

# កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០២១ រវាង

លោកស្រី **តោគ ស្រីទូច** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០៣០២៤១៨៧៦ (០១) ដែលមានតួនាទី **ប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **បាអាតហ្គុត ៦.ក** ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះ ផ្ទះលេខ១៣ ផ្លូវ៣៣៧ សង្កាត់ បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

និង

- **កញ្ញា អ៊ុក ស្រីនាង** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១៣៨២២០៣ ដែលមានតួនាទីជាអ្នកគ្រប់គ្រងភោជនីយដ្ឋាន និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។
- **លោក យ៉ាវ សំណាង** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១២៣៧៣២៣ ដែលមានតួនាទីជាប្រធានក្រុមផ្នែកចុងភៅចិន។

ភាគីទាំងបីបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

០១- **<u>រយៈពេលនៃការព្យួរកិច្ចសន្យាការងារ៖</u>**

ការព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី០៨ ខែ តុលា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០២១ ចំនួនកម្មករសរុប ១១៦ នាក់ ស្រី ៤៥នាក់ កម្មករព្យួរកិច្ចសន្យាការងារមាន ១៤នាក់ ស្រី ១០នាក់ មូលហេតុដោយសារ ក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ១៩។

០២- **<u>ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារ៖</u>**

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

០៣- **<u>កាលបរិច្ឆេទចូលបម្រើការងារវិញ៖</u>**

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។ កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្សីភាព៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០២១

តំណាងភាគីនិយោជិក | តំណាងប្រតិភូពេញសិទ្ធ

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន បាអាតហ្គុត ៦.ក BAATGOK CO., LTD. KINGDOM OF CAMBODIA

**កញ្ញា អ៊ុក ស្រីនាង** | **លោក យ៉ាវ សំណាង** | **លោកស្រី តោគ ស្រីទូច**